គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# សេចក្តីប្រកាស
## របស់គណបក្សប្រជាជនកម្ពុជា

ដោយបានឃើញព្រះរាជសារចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៨ របស់**ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ** ព្រះមហាក្សត្រជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជារាស្ត្រកម្ពុជាទូទាំងប្រទេស ដែលទ្រង់បានសព្វព្រះរាជហឫទ័យអំពាវនាវដោយព្រះរាជគតិបណ្ឌិតដ៏ឈ្លាសវៃ និងភ្លឺស្វាង ឱ្យកូន ចៅ ចៅទួតរបស់ព្រះអង្គ ចៀសវាងអំពើហិង្សា និងការបែកបាក់គ្នា នាំគ្នាដើរតាមគន្លងព្រះធម៌នៃព្រះពុទ្ធ ហើយគោរពតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ដើម្បីរួមគ្នាការពារឧត្តមប្រយោជន៍ជាតិ និងប្រជារាស្ត្រ ព្រមទាំងលើកកំពស់នូវកិត្តិនាមជាតិ ។

គណបក្សប្រជាជនកម្ពុជា សូមប្រកាសជាឱឡារិកដូចតទៅ :

១ - គណបក្សប្រជាជនកម្ពុជាស្មោះស្ម័គ្រគាំទ្រ ដោយឥតសំចៃ ចំពោះព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៨ ដែលជាប្រទីបដ៏សក្តិសិទ្ធិបំភ្លឺផ្លូវប្រជារាស្ត្រកម្ពុជា ឱ្យបានរួចចាកផុតពីវិបត្តិនយោបាយ វិបត្តិសេដ្ឋកិច្ច វិបត្តិសង្គម ព្រមទាំងមានឱកាសស្តារមុខមាត់ប្រទេសជាតិនៅលើឆាកអន្តរជាតិឡើងវិញ ។

គណបក្សប្រជាជនកម្ពុជាយល់ថា អ្នកដឹកនាំនយោបាយជាតិយើង ត្រូវតែរួបរួមគ្នាផ្តល់នូវសេចក្តីសង្ឃឹមថ្មី និងភាពកក់ក្តៅជាបន្ទាន់ ជូនប្រជាពលរដ្ឋជាម្ចាស់ឆ្នោត និងប្រជារាស្ត្រទូទៅ ចំពោះការដឹកនាំរដ្ឋាភិបាល ចំរុះថ្មីមួយនៅក្រោយការបោះឆ្នោតលើកនេះ ដែលត្រូវមកនូវសេចក្តីសុខក្សេមក្សាន្ត និងការរីកចំរើនជូនជាតិ មាតុភូមិជាទីស្នេហានៃយើង ។ នេះពុំត្រឹមតែ ជាឆន្ទៈរបស់ប្រជារាស្ត្រកម្ពុជាទាំងមូលប៉ុណ្ណោះទេ តែជាបំណងប្រាថ្នារបស់សហគមន៍អន្តរជាតិ រដ្ឋាភិបាល និងប្រទេសជាមិត្តរបស់យើងថែម

ទៀត ។ ការប្រកាន់ជំហរនយោបាយបន្តអរិភាព ឬរើសអើងណាមួយ ដែលដើរបញ្ច្រាសទិសនេះ ពិតជាគ្មានអនាគតឡើយ ។

២ - គណបក្សប្រជាជនកម្ពុជា សូមប្រកាសស្វាគមន៍គាំទ្រ ចំពោះព្រះរាជតំរិះដ៏ឧត្តុង្គឧត្តម ដែលអំពាវនាវឱ្យអ្នកនយោបាយជាតិយើង ប្រើការចរចាគ្នាជាភាតរៈវិញ ដើម្បីដោះស្រាយការខ្វែងគំនិតគ្នា និងស្រោចស្រង់ប្រទេសជាតិ ក្នុងកាលៈទេសៈដ៏លំបាកនេះ ។

គណបក្សប្រជាជនកម្ពុជា ត្រៀមខ្លួនរួចជាស្រេច ក្នុងការអនុវត្តន៍តាមព្រះរាជតំរិះមហាថ្លៃថ្លានេះ និងអំពាវនាវម្តងទៀត ចំពោះគណបក្ស ដែលមានអសនៈក្នុងរដ្ឋសភានីតិកាលទី២ មេត្តារួមគ្នាដោះស្រាយឱ្យបានឆាប់រហ័ស នូវបញ្ហាទាំងប៉ុន្មាន ដែលរាំងស្ទះដល់ការបង្កើតរាជរដ្ឋាភិបាលចំរុះថ្មី តាមផ្លូវនៃការចរចាគ្នាជាភាតរៈ ក្រោមព្រះរាជតួនាទីសំរបសំរួលដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ។

នេះជាមាគ៌ាដ៏មានកិត្តិយស ដែលយើងជាកូន ចៅ ចៅទួត របស់ព្រះអង្គត្រូវតែប្រញាប់ប្រញាល់បំពេញតាមព្រះរាជបំណងដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ដើម្បីរួបគ្នាបង្ហាញនូវភក្តីភាពប្តូរផ្តាច់ ចំពោះបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្រ រួមគ្នាលើកតំកើងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមានរបស់រដ្ឋ ហើយរួមគ្នាការពារតម្លៃនៃគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ។

ភ្នំពេញ,ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៨